# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៥៧...សសរ.

## សេចក្តីសំរេច

## ស្តីពីការបង្កើតក្រុមការងារពត៌មានវិទ្យាកម្ពុជា

៚៙៛

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសេចក្តីត្រូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមការងារពត៌មានវិទ្យាកម្ពុជា ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. ឯ.ឧ. **សេខ លឹមនៅ** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២. ឧត្តមសេនីយ៍ឯក **មាស សុភា** | អគ្គមេបញ្ជាការរង កងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក | អនុប្រធាន |
| ៣. ឯ.ឧ. **ណាត ប៊ុនរឿន** | អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៤. លោក **កេត សោផាន់** | ប្រធាននាយកដ្ឋានអាស៊ាន ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥. លោក **ខិម សិទ្ធី** | ប្រធាននាយកដ្ឋានពត៌មាន និង កិច្ចការអាស៊ាន ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៦. ឧត្តមសេនីយ៍ត្រី **ហ៊ឹ រដ្ឋា** | នាយកខុទ្ទកាល័យ បញ្ជាការដ្ឋានកងទ័ពជើងគោក ក្រសួងការពារជាតិ | សមាជិក |
| ៧. វរសេនីយ៍ឯក **ស៊ិន ច័ន្ទ** | នាយរងការិយាល័យទី ៤ បញ្ជាការដ្ឋានកងទ័ពជើងគោក ក្រសួងការពារជាតិ | សមាជិក |

**ប្រការ ២.-**

ក្រុមការងារនេះ មានភារកិច្ចដូចតទៅ :

- សំរបសំរួល និងធ្វើកិច្ចសហប្រតិបត្តិការជាមួយសមាគម អ៊ីនីស៊ីអេត-សិង្ហបុរី ( INITIATE-Singapore ) និងក្រុមហ៊ុនយ៉ុងភ៉ាកម្ពុជា ដើម្បីស្វែងរកជំនួយជាសំភារៈ និងឧបករណ៍ ព្រមទាំងអ្នកឯកទេស និងគ្រូបង្រៀនពតិមានវិទ្យា សំដៅបំពេញតំរូវការ និងរួមចំណែកដល់ការបណ្តុះបណ្តាលវិស័យពតិមានវិទ្យា ដល់មន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងអប់រំ នាយទាហាន ពលទាហាន នៃបញ្ជាការដ្ឋានកងទ័ពជើងគោក និង គរុសិស្ស សិស្សានុសិស្ស នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

- តាមដាននិងត្រួតពិនិត្យដំណើរការបណ្តុះបណ្តាល នៅក្នុងស្ថាប័នទាំងបីនេះ ដើម្បីធានាអោយមាន ប្រសិទ្ធភាពខ្ពស់ ក្នុងការអភិវឌ្ឍធនធានមនុស្ស ក្នុងវិស័យពតិមានវិទ្យា។

**ប្រការ ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មេបញ្ជាការកងទ័ព ជើងគោក និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

ភ្នំពេញថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន:**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងអប់រំ យុវជន និងកីឡា
- បញ្ជាការដ្ឋានកងទ័ពជើងគោក
- ដូចប្រការ ១
- ឯកសារ-កាលប្បវត្តិ